Human & Hope Association

Empowering Cambodians to create a sustainable future

# ក្រមសីលធម៌សម្រាប់ភ្ញៀវដែលមកទស្សនាសមាគម

គោលបំណងដែល **សមាគម មនុស្ស និងក្តីសង្ឃឹម** បង្កើតក្រមសីលធម៌នេះឡើងគឺដើម្បីការពារកុមារពីការរំលោភបំពានផ្សេងៗ ព្រមទាំងតម្រូវឲ្យភ្ញៀវបង្ហាញនូវឥរិយាបថឲ្យបានសមរម្យ ចៀសវាងការមានកំហុសផ្សេងៗជាមួយកុមារ ។ យើងធ្វើការជាមួយប្រជាជន និងក្មេងៗក្នុងសហគមន៍ ដូច្នេះយើងចង់ឲ្យពួកគាត់ទទួលបាននូវសុខសុវត្ថិភាពគ្រប់ពេលវេលា ដើម្បីបង្ហាញនូវការគោរព និងឲ្យតម្លៃដល់ពួកគាត់ ។

ក្រមសីលធម៌សម្រាប់ភ្ញៀវដែលមកទស្សនា **សមាគម មនុស្ស និងក្តីសង្ឃឹម** នេះគឺនឹងដាក់ឲ្យភ្ញៀវប្រើប្រាស់គ្រប់ៗគ្នា ។ ភ្ញៀវទាំងអស់ត្រូវតែអនុវត្តទៅតាមក្រមសីលធម៌នេះ ដូចខាងក្រោម៖

- ភ្ញៀវទាំងអស់ដែលមកសមាគម តម្រូវឲ្យធ្វើការណាត់ជួបជាមួយអ្នកគ្រប់ជាមុន
- ភ្ញៀវទាំងអស់គួរតែសម្តែងការស្វាគមន៍បុគ្គលិក និងសិស្សដោយការសំពះ ស្របទៅតាមវប្បធម៌របស់ខ្មែរ ដោយមិនគួរចាប់ដៃ ឱប ឬថើបឡើយ
- ការទស្សនាជាក្រុម មិនអាចលើសពី៥នាក់ឡើយ លុះត្រាតែមានករណីពិសេសណាមួយ
- ភ្ញៀវទាំងអស់ត្រូវតែពាក់កាតដែលយើងផ្តល់ឲ្យ និងប្រគល់មកវិញពេលត្រឡប់មកវិញ
- ភ្ញៀវទាំងអស់ត្រូវស្លៀកសម្លៀកបំពាក់ឲ្យបានសមរម្យ ដោយមិនមានភាពស៊ិចស៊ីឡើយ
- ភ្ញៀវទាំងអស់ត្រូវតែដើរអមដោយបុគ្គលិកសមាគមគ្រប់ពេល ហើយភ្ញៀវមិនអាចនៅជាមួយក្មេងតែម្នាក់ឯង ជាដាច់ខាត
- ថតវីឌីអូ ឬថតរូបភាពក៏មិនអនុញ្ញាតឲ្យថតផងដែរ
- ភ្ញៀវទាំងអស់មិនអនុញ្ញាតឲ្យចូលនៅក្នុងថ្នាក់រៀនភាសា នៅពេលសិស្សកំពុងរៀនឡើយ
- ភ្ញៀវទាំងអស់មិនអាចឲ្យកាដូដល់សិស្សដោយផ្ទាល់នោះទេ ។ ប្រសិនបើអ្នកចង់បរិច្ចាគ អ្នកអាចប្រគល់ជូនអ្នកគ្រប់គ្រងរបស់សមាគម
- យើងមានសិទ្ធិបដិសេធមិនអនុញ្ញាតឲ្យទស្សនា ចំពោះអ្នកដែលមិនបានអនុវត្តទៅតាមក្រមសីលធម៌នេះ
- សមាគម នឹងរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ចំពោះភ្ញៀវដែលនៅតែបន្តប្រព្រឹត្តខុសនឹងក្រមសីលធម៌នេះ
- អ្នកគ្រប់គ្រងមានសិទ្ធិបដិសេធ ឬលុបចោលការទស្សនាគ្រប់ពេល ដោយយោងទៅតាមការប្រព្រឹត្តរបស់ភ្ញៀវ ដោយគ្មានការចោទជាសំណួរឡើយ
- ភ្ញៀវទាំងអស់មិនអនុញ្ញាតនាំយកសិស្សសមាគមចេញទៅក្រៅដូចជា ទៅដើរលេង ទៅបរិភោគអាហារពេលល្ងាច ទៅមើលកុន ទៅទិញឥវ៉ាន់ - ល- ដែលទង្វើទាំងនេះសមាគមហាមប្រាមយ៉ាងតឹងរឹងជាទីបំផុត ។